ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៧

លេខ: ... ក្រសួងមុខងារសាធារណៈ រដ្ឋបាល
ចូល លេខ: ៥០៤១ មកដល់ថ្ងៃទី០៥ ខែ០៣ ឆ្នាំ២០១៧ ម៉ោង ៨:០៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឲ្យចូលបម្រើការងារ នៅក្នុងក្របខណ្ឌក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់ឆ្នាំ ២០១៧

**យោង៖** លិខិតលេខ ៤៨៧ មស.ក្រខ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមប្រកាសជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការ ទាំងពីរភេទ ឲ្យបានជ្រាបថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនឹងរៀបចំការប្រឡងជ្រើសរើសបេក្ខជនឲ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងតាមចំនួន និងលក្ខខណ្ឌដូចខាងក្រោម ៖

**១.ថ្នាក់រដ្ឋបាលកណ្តាល ៖**

ចំនួនជ្រើសរើស **សរុប ៣៣ កន្លែង** ដោយចែកចេញតាមមុខជំនាញ-ឯកទេស ដូចខាងក្រោម ៖

| ល.រ | មុខជំនាញ-ឯកទេស | ចំនួនជ្រើសរើស សរុប | ចំនួនជ្រើសរើស តាមក្របខណ្ឌ | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ក | ខ | គ | |
| ១ | បុរាណវិទ្យា | ៤ | ៤ | | | |
| ២ | សិល្បៈសូនរូប (Design) | ១ | ១ | | | សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ |
| ៣ | សិល្បៈសូនរូប (ចម្លាក់ស្មិត) | ១ | | ១ | | |
| ៤ | នាដសាស្ត្រ | ១ | ១ | | | |
| ៥ | នាដសាស្ត្រ (ល្ខោនយីកេ) | ១ | | ១ | | |
| ៦ | នាដសាស្ត្រ (របាំប្រពៃណី) | ៤ | | ៤ | | |
| ៧ | តន្ត្រី (រនាត) | ១ | ១ | | | |
| ៨ | តន្ត្រី (ទ្រ) | ១ | | ១ | | |
| ៩ | រដ្ឋបាលសាធារណៈ | ៣ | ៣ | | | |
| ១០ | នីតិសាស្ត្រ | ២ | ២ | | | |

| ល.រ | មុខជំនាញ-ឯកទេស | ចំនួនជ្រើសរើសសរុប | ចំនួនជ្រើសរើសតាមក្របខណ្ឌ | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ក | ខ | គ | |
| ១១ | ទំនាក់ទំនងការទូត | ២ | ២ | | | |
| ១២ | ស្រាវជ្រាវវិទ្យាសាស្ត្រ | ១ | ១ | | | |
| ១៣ | គណនេយ្យ និងហិរញ្ញវត្ថុ | ៦ | ៦ | | | |
| ១៤ | ព័ត៌មានវិទ្យា | ២ | ២ | | | |
| ១៥ | ភាសាអង់គ្លេស | ១ | ១ | | | |
| ១៦ | វិស្វកម្មសំណង់ | ១ | ១ | | | |
| ១៧ | វិស្វកម្មអគ្គិសនី | ១ | ១ | | | |
| **សរុប** | | ៣៣ | ២៦ | ៧ | | |

## ២.ថ្នាក់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖

ចំនួនជ្រើសរើស **សរុប ៦០ កន្លែង** ដោយចែកចេញដូចខាងក្រោម ៖

| ល.រ | មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | ឯកទេស-ជំនាញ | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | | |
|---|---|---|---|---|---|---|
| | | | | ក | ខ | គ |
| ១ | រាជធានីភ្នំពេញ | បុរាណវិទ្យា | ១ | ១ | | |
| | | នាដសាស្ត្រ (ល្ខោនខោល) | ១ | | ១ | |
| | | នាដសាស្ត្រ (ល្ខោនបាសាក់) | ១ | | ១ | |
| | | សិល្បៈសូនរូប (ចម្លាក់ពុម្ពស៊ីម៉ង់ត៍) | ១ | | ១ | |
| | | លេខាធិការ | ១ | | | ១ |
| ២ | ខេត្ត កណ្ដាល | បុរាណវិទ្យា | ១ | ១ | | |
| | | គណនេយ្យ និងហិរញ្ញវត្ថុ | ១ | ១ | | |
| | | តូរ្យតន្ត្រី (បុរាណ) | ១ | | ១ | |
| | | គ្រប់គ្រង | ១ | | ១ | |
| | | លេខាធិការ | ១ | | | ១ |
| ៣ | ខេត្ត កែប | គណនេយ្យ | ១ | ១ | | |
| | | លេខាធិការ | ១ | | | ១ |
| ៤ | ខេត្ត កំពង់ចាម | ស្ថាបត្យកម្ម | ១ | ១ | | |
| | | គ្រប់គ្រង | ១ | | ១ | |
| | | ភាសាអង់គ្លេស | ១ | | ១ | |
| | | លេខាធិការ | ១ | | | ១ |

| ល.រ | មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | ឯកទេស-ជំនាញ | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | | |
|---|---|---|---|---|---|---|
| | | | | ក | ខ | គ |
| ៥ | ខេត្ត កំពង់ឆ្នាំង | បុរាណវិទ្យា | ១ | ១ | | |
| | | លេខាធិការ | ១ | | | ១ |
| ៦ | ខេត្ត កំពង់ធំ | ស្ថាបត្យកម្ម | ១ | ១ | | |
| | | នាដសាស្ត្រ | ១ | | ១ | |
| | | លេខាធិការ | ១ | | | ១ |
| ៧ | ខេត្ត កំពង់ស្ពឺ | គណនេយ្យ | ១ | ១ | | |
| | | នាដសាស្ត្រ (របាំប្រពៃណី) | ១ | | ១ | |
| ៨ | ខេត្ត កំពត | ស្ថាបត្យកម្ម | ១ | ១ | | |
| | | លេខាធិការ | ១ | | | ១ |
| ៩ | ខេត្ត កោះកុង | គ្រប់គ្រង | ១ | ១ | | |
| | | លេខាធិការ | ១ | | | ១ |
| ១០ | ខេត្ត ក្រចេះ | បុរាណវិទ្យា | ១ | ១ | | |
| ១១ | ខេត្ត តាកែវ | គណនេយ្យ | ១ | ១ | | |
| | | សិល្បៈសូនរូប | ១ | | ១ | |
| | | នាដសាស្ត្រ | ២ | | ២ | |
| | | លេខាធិការ | ១ | | | ១ |
| ១២ | ខេត្ត ត្បូងឃ្មុំ | បុរាណវិទ្យា | ១ | ១ | | |
| | | សិល្បៈសូនរូប (គំនូរ និងចម្លាក់) | ១ | | ១ | |
| | | នាដសាស្ត្រ (របាំប្រពៃណី) | ១ | | ១ | |
| | | រដ្ឋបាលសាធារណៈ | ១ | | ១ | |
| | | គ្រប់គ្រងពាណិជ្ជកម្ម | ១ | | ១ | |
| ១៣ | ខេត្ត បន្ទាយមានជ័យ | ស្ថាបត្យកម្ម | ១ | ១ | | |
| ១៤ | ខេត្ត បាត់ដំបង | ស្ថាបត្យកម្ម | ១ | ១ | | |
| | | លេខាធិការ | ២ | | | ២ |
| ១៥ | ខេត្ត ប៉ៃលិន | លេខាធិការ | ១ | | | ១ |
| ១៦ | ខេត្ត ពោធិ៍សាត់ | *សញ្ញាបត្រសមស្រប ដូចមានក្នុងសេចក្តីជូនដំណឹងនេះ* | ១ | ១ | | |
| | | លេខាធិការ | ១ | | | ១ |
| ១៧ | ខេត្ត ព្រៃវែង | បុរាណវិទ្យា | ១ | ១ | | |
| | | គណនេយ្យ | ១ | | ១ | |

| ល.រ | មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | ឯកទេស-ជំនាញ | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | | |
|---|---|---|---|---|---|---|
| | | | | ក | ខ | គ |
| ១៨ | ខេត្ត ព្រះវិហារ | បុរាណវិទ្យា | ១ | ១ | | |
| | | លេខាធិការ | ១ | | | ១ |
| ១៩ | ខេត្ត ព្រះសីហនុ | ព័ត៌មានវិទ្យា | ១ | ១ | | |
| | | លេខាធិការ | ១ | | | ១ |
| ២០ | ខេត្ត មណ្ឌលគិរី | នាដសាស្ត្រ | ១ | ១ | | |
| ២១ | ខេត្ត រតនគិរី | ព័ត៌មានវិទ្យា | ១ | ១ | | |
| ២២ | ខេត្ត សៀមរាប | *សញ្ញាបត្រសមស្រប ដូចមានក្នុងសេចក្តីជូនដំណឹងនេះ* | ៣ | ២ | ១ | |
| | | លេខាធិការ | ១ | | | ១ |
| ២៣ | ខេត្ត ស្ទឹងត្រែង | បុរាណវិទ្យា | ១ | ១ | | |
| ២៤ | ខេត្ត ស្វាយរៀង | គណនេយ្យ និងហិរញ្ញវត្ថុ | ១ | ១ | | |
| ២៥ | ខេត្ត ឧត្តរមានជ័យ | ស្ថាបត្យកម្ម | ១ | ១ | | |
| **សរុប** | | | **៦០** | **២៦** | **១៨** | **១៦** |

**៣.លក្ខខណ្ឌនៃការប្រឡងជ្រើសរើស ៖**

៣.១.បេក្ខជនត្រូវមានសញ្ជាតិខ្មែរ

៣.២.ចំពោះបេក្ខជនជាសិស្ស និស្សិតការកំណត់អាយុដូចមានខាងក្រោម៖

- ក្របខណ្ឌប្រភេទ **ក** បេក្ខជនត្រូវមានអាយុមិនលើសពី ៣៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ករណីមានសញ្ញាបត្របរិញ្ញាបត្រ។

- ក្របខណ្ឌប្រភេទ **ក** បេក្ខជនត្រូវមានអាយុមិនលើសពី ៤០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ករណីមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។

- បេក្ខជនជានិស្សិតដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

- ក្របខណ្ឌប្រភេទ **ខ** បេក្ខជនត្រូវមានអាយុមិនលើសពី ២៨ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ហើយត្រូវមានសញ្ញាបត្របរិញ្ញាបត្ររង ស្នាតកបត្រសិល្បៈ ឬសញ្ញាបត្រសមមូល។

- ក្របខណ្ឌប្រភេទ **គ** បេក្ខជនត្រូវមានអាយុមិនលើសពី ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ហើយត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល។

៣.៣.ចំពោះបេក្ខជនជាមន្ត្រីរាជការស៊ីវិល ត្រូវមានលក្ខខណ្ឌដូចមានខាងក្រោម៖

- លក្ខខណ្ឌអាយុត្រូវបានលើកលែង។

- ត្រូវមានសញ្ញាបត្រសមស្របតាមមុខជំនាញ-ឯកទេស ដូចមានកំណត់ក្នុងសេចក្តីជូនដំណឹងនេះ។

- ត្រូវមានលិខិតអនុញ្ញាតឲ្យចូលរួមប្រឡងប្រជែងពីប្រធានក្រសួង ស្ថាប័នសាមី និងត្រូវអនុញ្ញាតឲ្យផ្ទេរក្របខណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការនៅពេលប្រឡងជាប់ជាស្ថាពរ។

***បញ្ជាក់*** ***៖ បេក្ខជនជាមន្ត្រីរាជការដែលប្រឡងជាប់ជាស្ថាពរ នឹងត្រូវបានរក្សាទុកអតីតភាពការងារជូន តែមិនរក្សាទុកមុខតំណែង-តួនាទីឡើយ។***

៣.៤.មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ។

៣.៥.ចំពោះបេក្ខជនជានារី ជនពិការ អ្នករស់នៅតំបន់ដាច់ស្រយាល ជនជាតិភាគតិច និងមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត។

## ៤.កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យសុំសិទ្ធិប្រឡង ៖

កាលបរិច្ឆេទទទួលពាក្យចុះឈ្មោះប្រឡង គិតចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់**ថ្ងៃព្រហស្បតិ៍ ទី២៧ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ១៧:០០ល្ងាច។**

- បេក្ខជនត្រូវមកដាក់ពាក្យដោយខ្លួនឯងផ្ទាល់នៅការិយាល័យបៀវត្ស-ក្របខណ្ឌនាយកដ្ឋានបុគ្គលិក នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាន់ទី៣ (បន្ទប់លេខ ៣០១) ពេលព្រឹកពីម៉ោង ៨:០០ ដល់ ១១:៣០នាទី ពេលរសៀលពីម៉ោង ១៤:០០ ដល់ ១៧:០០នាទី។

## ៥.សំណុំលិខិតសុំចុះឈ្មោះប្រឡង ៖

| | |
|---|---|
| - ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ ច្បាប់ |
| - ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី(ផ្ទៃស) (៤ x ៦) | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យាបម្រើការងារក្រសួង | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្រឯកត្តជន មានបិទរូបថតថ្មី (ផ្ទៃស) (៤ x ៦) | ចំនួន ០១ ច្បាប់ |
| - សេចក្តីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងសញ្ញាបត្រជំនាញ "ដែលមានបញ្ជាក់ជាផ្លូវការ" | ចំនួន ០១ ច្បាប់ |
| - សេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណបណ្ណ "ជាផ្លូវការ" | ចំនួន ០១ ច្បាប់ |
| - បង្កាន់ដៃបង់សិទ្ធិប្រឡង | ចំនួន ០១ ច្បាប់ |
| - លិខិតបញ្ជាក់ចេញដោយក្រសួង ស្ថាប័នសាមី (សម្រាប់មន្ត្រីរាជការ) | ចំនួន ០១ ច្បាប់ |
| - រូបថតថ្មី (ផ្ទៃស) ៤ x ៦ "ថតចំពីមុខ" | ចំនួន ០៣ សន្លឹក |
| - លិខិតបញ្ជាក់សុខភាព "ក្រោយពេលប្រឡងជាប់" (ពីក្រសួងការងារ) | ចំនួន ០១ ច្បាប់ |
| - លិខិតថ្កោលទោស "ក្រោយពេលប្រឡងជាប់" | ចំនួន ០១ ច្បាប់ |

### ៦.អំពីវិញ្ញាសាប្រឡង ៖

#### ៦.១.ម៉ោងទី១ ៖

កម្រិតឧត្តម ក្របខណ្ឌ (ក) និងមធ្យម ក្របខណ្ឌ (ខ) ៖

- ភាសាអង់គ្លេស (ខ្លឹមសារទាក់ទងនឹងវិស័យវប្បធម៌)................................ **រយៈពេល ២ ម៉ោង**

កម្រិតបឋម ក្របខណ្ឌ (គ) ៖

- វប្បធម៌ទូទៅ........................................................................................ **រយៈពេល ២ ម៉ោង**

#### ៦.២. ម៉ោងទី២ ៖

កម្រិតឧត្តម ក្របខណ្ឌ (ក) និងមធ្យម ក្របខណ្ឌ (ខ) ៖

- មុខជំនាញ-ឯកទេស (សម្រាប់និស្សិត)........................................ **រយៈពេល ២ ម៉ោង**
- ចំណេះដឹងទូទៅនីតិមុខងារសាធារណៈ (សម្រាប់មន្ត្រីរាជការ)................ **រយៈពេល ២ ម៉ោង**
- នាដសាស្ត្រ, តូរ្យតន្ត្រី កម្រិតមធ្យម (អនុវត្តផ្ទាល់).................................. **រយៈពេល ២ ម៉ោង**

### ៧.កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង ៖

សម្រាប់កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងជូនដំណឹងនៅពេលក្រោយ។

បេក្ខជនទាំងអស់អាចទាញយកពាក្យសុំសិទ្ធិប្រឡងតាមរយៈគេហទំព័ររបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (www.mcfa.gov.kh)។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមទូរស័ព្ទ កញ្ញា ស៊ូ សុធា ០១១ ៦៣២ ២០២, លោក កែ ជានិត ០៩៩ ៥០១ ៥០០។

រដ្ឋមន្ត្រី

ភឿង - សកុណា

**ចម្លងជូន ៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីរមុខងារសាធារណៈរាជធានី-ខេត្ត
- គ្រប់អង្គភាពចំណុះក្រសួង
  និងគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ